ខែ4 ឆ្នាំ2022
សមាគមGTS

# ជូនទៅកាន់កម្មសិក្សាការីទាំងអស់គ្នា

ពេលនេះគឺជារដូវរំហើយ ជាពេលដែលពោរពេញទៅដោយផ្ការីកនៅប្រទេសជប៉ុន ។
តើអ្នកទាំងអស់គ្នានៅប្រទេសជប៉ុនដោយសុខសប្បាយជាតិទេ?
ចំនួនអ្នកឆ្លងវីរុសកូរ៉ូណាថ្មីនៅតែមានច្រើន។ សូមចាត់វិធានការការពារ និងទប់ស្កាត់អោយបានល្អទាំងអស់គ្នារដូវកាលនេះក៏ជារដូវកាលដែលមានការផ្លាស់ប្តូរសីតុណ្ហភាពខ្លាំង។ សីតុណ្ហភាពទាបនៅ
ពេលព្រឹកនិងពេលល្ងាច ហើយអំឡុងពេលថ្ងៃត្រង់សីតុណ្ហភាពអាចកើនឡើងដូចរដូវក្តៅ។ អាស្រ័យទៅតាមអាកាសធាតុ ពេលថ្ងៃត្រង់ខ្លះក៏អាចនឹងត្រជាក់ផងដែរ។ សូមរក្សាសុខភាពដោយកុំឲ្យមានជំងឺឈឺស្កាត់។

ជិតដល់ថ្ងៃឈប់សម្រាក់មួយសប្តាហ៍ហើយ សូមអ្នកទាំងអស់គ្នាប្រកាន់នូវអកប្បកិរិយាសមរម្យ និងប្រកាន់នូវឲ្យទំលាប់ល្អក្នុងការរស់នៅប្រចាំថ្ងៃ។
ទោះជានៅក្នុងកាលៈទេសណាក៏ដោយតើអ្នកអាចឆ្លើយដោយមានជំនឿចិត្តបានទេ
ថាអ្នកអាចក្លាយជាសិស្សច្បងគំរូបាន?
សូមរស់នៅប្រទេសជប៉ុនដោយមានមោទនភាពហើយគិតថាខ្លួនយើងម្នាក់ៗតំណាងឲ្យប្រទេសកម្ពុជា។ ប្រសិនបើអ្នកបំពានច្បាប់ ជនជាតិជប៉ុននឹងមានគំនិតថាមិនមែនត្រឹមតែអ្នកជាមនុស្សមិនល្អទេ ជនជាតិជប៉ុននឹងគិតថាជនជាតិកម្ពុជាទាំងអស់ជាមនុស្សមិនល្អ។
សកម្មភាពមិនល្អរបស់មនុស្សម្នាក់អាចនាំឲ្យ គេគិតថាជនជាតិរបស់អ្នកមិនល្អ ។
សូមរស់នៅប្រទេសជប៉ុនដោយមោទនភាពថាខ្លួនជាអ្នកតំណាងដោយប្រទេសម្នាក់។
កុំក្បត់អ្នកដែលកំពុងថែរក្សាអ្នក។ ប្រសិនបើអ្នកបាត់បងការជឿជាក់តែម្តង អ្នកនឹងមិនអាចរកវាមកវិញទេ។ ដូចនេះសូមប្រុងប្រយ័ត្នរាល់សកម្មភាពរបស់អ្នក។

កំណត់ចំណាំ

## 1.អំពីការការពារការឆ្លងមេរោគកូរ៉ូណាថ្មី

- ពាក់ម៉ាស, ជៀសវាងការនិយាយជាមួយមនុស្សដោយមិនបានពាក់ម៉ាស
- រក្សាគម្លាតរវាងគ្នានឹងគ្នាចាប់ពី១ម៉ែតឡើងទៅ
- ជៀសវាងការជួបជុំទ្រង់ទ្រាយធំនិងពិធីជប់លៀងផឹកស៊ីរយៈពេលយូរ
- បន្ទប់ពេលដែលមិនប្រើត្រូវបើបង្អួចអោយជំៗជាដើម, ធ្វើឱ្យខ្យល់ចេញចូលទោះបីជាបរិយាកាសត្រជាក់ក៏ដោយ។

https://www.otit.go.jp/CoV2_jissyu_kansen/ ←សូមពិនិត្យនៅទីនេះ សំរាប់ការបញ្ជាក់បន្ថែម

## 2.អំពីជំងឺ

ការការពារជំងឺផ្តាសាយ ផ្តាសាយធំប្រភេទថ្មី

- ពេលត្រលប់មកពីខាងក្រៅ, មុនចំអិនអាហារដាច់ខាតត្រូវលាងដៃនិងខ្ពុរមាត់។

・ត្រូវរស់នៅដោយត្រឹមត្រូវទៅតាមច្បាប់ ០០:(កុំនៅដល់យប់ជ្រៅពេក)
・ត្រូវយកចិត្តទុកដាក់ទៅលើរបបអាហារញ៉ាំដែលផ្តល់ជីវជាតិគ្រប់គ្រាន់។

3.អំពីគ្រោះថ្នាក់ចរាចរ

ប្រុងប្រយ័ត្នកុំឱ្យជួបគ្រោះថ្នាក់ចរាចរណ៍
អ្នកត្រូវប្រកាន់និងគោរពច្បាប់ចរាចរជប៉ុនឲ្យបានយ៉ាងខ្ជាប់ខ្ជួន ។
ប្រសិនបើគ្រោះថ្នាក់គួរកើតឡើង ...
នោះជានៅក្នុងស្ថានភាពយ៉ាងណាក៏ដោយត្រូវតាំងចិត្ត កុំភ័យ ហើយទាក់ទងទៅកាន់ខាងសមាគមឬបុគ្គលិកកម្ពុជានៅប្រទេសជប៉ុន អ្នកក៏ត្រូវយកប័ណ្ណស្នាក់នៅជាប់ជានិច្ច។
ត្រូវគោរពច្បាប់ជិះកង់ទាំងអស់គ្នា។ ការគោរពច្បាប់ចរាចរស្មើនឹងការពារអាយុជីវិតខ្លួនឯង។

4.អំពីរញ្ជួយដី

ប្រទេសជប៉ុនត្រូវបានគេដឹងថាជាប្រទេសដែលមានការរញ្ជួយដីជាច្រើន។
ប្រសិនបើមានការរញ្ជួយដីកើតមានឡើងតើអ្នកគួរធ្វើអ្វី? តើអ្នកទាំងអស់គ្នាដឹងដែរឬទេ?
បន្ទាប់ពីអ្នកមើលសៀវភៅ（ http://www.fdma.go.jp/bousai_manual/index.html ）
ស្តីពីសៀវភៅណែនាំអំពីការការពារគ្រោះមហន្តរាយរបស់ទីភ្នាក់ងារគ្រប់គ្រងគ្រោះមហន្តរាយនិងទីភ្នាក់ងារអគ្គីភ័យ អ្នកនឹងទទួលបានទទួលចំណេះដ៏ល្អ។

5.អំពីការងារក្រៅម៉ោង

ការងារក្រៅម៉ោងនិងការងារធ្វើតាមផ្ទះ ត្រូវបានហាមឃាត់មិនឲ្យកម្មសិក្សាការីធ្វើនោះទេ!
ថ្វីបើទទួលបានសិទ្ធស្នាក់នៅក៏ដោយ មានន័យថាអ្នកជាកម្មសិក្សាការីកហាត់ជំនាញគឺ "ការហ្វឹកហ្វឺនបច្ចេកទេសលេខ 1R" និង "ការហ្វឹកហ្វឺនបច្ចេកទេសលេខ 2 R"។
ការទទួលយកប្រាក់ឈ្នួលនៅតាមគ្រឹះស្ថាននិងហាងផ្សេងៗគឺជាសកម្មភាពខុសច្បាប់ ហើយនឹងបណ្តាលឲ្យក្រុមហ៊ុននិងសមាគមរបស់អ្នកត្រូវទទួលទោសផងដែល!
លើសពីនេះទៅទៀតវាជាសកម្មភាពមួយខុសពីការហ្វឹកហ្វឺនជំនាញជាក់ស្តែង ហើយអ្នកនឹងត្រូវបញ្ជូនវិលត្រឡប់ទៅផ្ទះវិញ។

6.ផ្សេងៗ

ត្រូវដាច់ខាត់គោរពច្បាប់ក្រុមហ៊ុនច្បាប់ ច្បាប់នៅកន្លែងស្នាក់នៅ និងច្បាប់របស់ប្រទេសជប៉ុន។
ឧក្រិដ្ឋជនត្រូវបានដាក់ទោសដោយមិនគិតពីជនជាតិជប៉ុនឬជនបរទេសឡើយ។
ប្រសិនបើអ្នកធ្លាប់ជាប់បទព្រហ្មទណ្ឌហើយ អ្នកនឹងមិនអាចលុបប្រវត្តិនោះបានទេ។
・ហាមឃាត់ការស្នាក់ខាងក្រៅដោយមិនមានការអនុញ្ញាត។ ចូរសុំច្បាប់ពីក្រុមហ៊ុន ឬសមាគមជាមុនសិន។
(ជួនកាលក៏អាចនឹងមិនទទួលបានការអនុញ្ញាត្តិដែរ ដូចនេះសូមធ្វើតាមការណែនាំ)
・គ្រូបង្រៀនណែនាំការរស់នៅអាចនឹងដើរត្រួតពិនិត្យកន្លែងស្នាក់នៅគ្រប់ពេល ! ប្រសិនបើមានបញ្ហា អ្នកត្រូវតែទាក់ទងទៅសមាគមផង។វានឹងមានការលំបាកស្នើសុំបច្ចុប្បន្នភាព VISA ទៅកាន់អន្តោប្រវេសន៍ ប្រសិនបើអ្នកត្រូវបានគេបញ្ជាក់ថាអាកប្បកិរិយាក្នុងការរស់នៅរបស់អ្នកមិនល្អ។
នេះជាច្បាប់ដើម្បីឲ្យអ្នកទាំងអស់គ្នានៅប្រទេសជប៉ុនដោយសុវត្ថិភាពតែប៉ុណ្ណោះ !
ដូចនេះហើយអ្នកត្រូវគោរពវិន័យ ហើយកុំសប្បាយមួយពេលដែលធ្វើឲ្យអ្នកខូចអនាគត !

ការលួចទំនិញតាមហាង

និងជិះកង់ដែលគេទុកចោលទាំងនេះគឺជាអំពើខុស

ច្បាប់ ដែលមិនអាចលើកលែងបាន !

ជាអកុសលមានការកើនឡើងចំនួនករណីឧក្រិដ្ឋកម្មដែលបង្ករដោយជនថៃក្នុងពេលរឹកហាត់ជំនាញ
 !
មិនត្រូវជឿពាក់លួងលោមសូម្បីតែជាជនជាតិដូចគ្នា។ពាក្យផ្អែមល្ហែមគឺជាអន្ទាក់។សូមជឿជាក់លើខ្លួនឯង !

មិនត្រូវឲ្យលិខិតឆ្លងដែននិងប័ណ្ណស្នាក់ទៅកាន់នរណាម្នាក់ក្រៅពីសមាគម ឬក្រុមហ៊ុនទេ !

អ្នកនឹងមិនតម្រូវឲ្យស្នើរដោយផ្ទាល់ខ្លួននៅខាងអន្តោប្រវេសន៍ទេ។ជនខិលខូចតែងតែចង់បានលិខិតឆ្លងដែន
ឬប័ណ្ណស្នាក់នៅរបស់អ្នក! សូមប្រុងប្រយ័ត្ន!

ចប់